# កាយវិការព្រះពុទ្ធក្នុងសិល្បៈខ្មែរ

ព្រះពុទ្ធសមណគោត្តម មានព្រះនាមថាសិទ្ធត្ថ ទ្រង់ប្រសូតក្នុងខែឧសភា ឆ្នាំ៦២៣ មុនគ្រិស្តសករាជ។[១] ព្រះអង្គចេញចាកផ្នួសនៅខែកក្កដា[២] ក្នុងព្រះជន្ម២៩ព្រះវស្សាត្រាស់ដឹងក្នុងព្រះជន្ម៣៥ព្រះវស្សា[៣] ហើយចូលបរិនិព្វានក្នុងព្រះជន្ម៨០ព្រះវស្សា។

ការចូលបរិនិព្វានរបស់ព្រះពុទ្ធ គឺជាការបាត់បង់យ៉ាងធំធេងរបស់ពុទ្ធសាសនិក ដូច្នេះដើម្បីរំលឹកដល់ព្រះវត្តមាន និងព្រះធម៌របស់ព្រះអង្គ សាសនិកបានបង្កើតបដិមាតំណាងឱ្យព្រះអង្គ។ ក្នុងសិល្បៈព្រះពុទ្ធសាសនាដំបូងៗដូចជានៅ បរហ៊ូត សាន់ឈី ពុទ្ធកាយា អមរាវតី និងណាហ្គាជុនកុនដាជាដើម បដិមាព្រះពុទ្ធគ្មានទម្រង់ជាមនុស្សដូចសព្វថ្ងៃនេះទេ[៤] ប៉ុន្តែជារូបតំណាងដូចជា កង់ចក្រ ដើមពោធិ បល្ល័ង្ក ចេតិយ ឆ័ត្រ និងពុទ្ធបាទ។[៥] តាមរយៈអត្ថបទល្បីៗរបស់ពុទ្ធសាសនាដូចជា Brahmajala Sutta, Samyutta Nikaya, Majjima Nikaya, Divyavadana និងAvadanakalpalata បង្ហាញថាការគោរពបដិមាព្រះពុទ្ធផ្តើមឡើងនៅរវាងសតវត្សទី១មុនគ្រិស្តសករាជ។ ផ្ទុយទៅវិញ បើតាមគម្ពីរភាសាសំស្ក្រឹតដូចជា Tathagata-Prativimba-Pratisthanusamsa បញ្ជាក់ថាការគោរពបដិមាព្រះពុទ្ធផ្តើមឡើងនៅរវាងសតវត្សទី១នៃគ្រិស្តសករាជ។[៦]

បដិមាព្រះពុទ្ធក្នុងទម្រង់ជាមនុស្ស បានបង្កើតឡើងស្របទៅតាមបរិបទសង្គម នៃប្រទេសកាន់ពុទ្ធសាសនានីមួយៗ។ គេឃើញថាមានទម្រង់ និងកាយវិការរួមបីគឺ ឈរ អង្គុយ និងចូលបរិនិព្វាន។[៧]

## តើព្រះពុទ្ធបដិមានៅស្រុកខ្មែរមានទម្រង់កាយវិការដូចម្តេចខ្លះ?

ក្នុងដំណើរជីវិតរបស់ព្រះពុទ្ធមានព្រឹត្តិការណ៍ពិសេសៗជាច្រើន បានកើតឡើងដែលនេះជាគំរូសម្រាប់កសាងបដិមារបស់ទ្រង់។

---

[១] Abeysekera, *The Life of the Buddha*, 13.
[២] Abeysekera, 19.
[៣] Abeysekera, 26.
[៤] Padmanabha, 'The Buddha Image in Sculptural Arts of India', 94.
[៥] Huntington, 'Early Buddhist Art and the Theory of Aniconism', 2.
[៦] Padmanabha, 'The Buddha Image in Sculptural Arts of India', 93.
[៧] Padmanabha, 94.

អត្ថបទដោយ៖ មាស សុភាព

## ១. ព្រះពុទ្ធទ្រង់ឈរ

ព្រះពុទ្ធបដិមាទ្រង់ឈរទំនងជាបង្កើតឡើងដំបូងនៅតំបន់អមរាវតី (Amarāvati) នៅឯស្រុកឥណ្ឌា ក៏ប៉ុន្តែមិនមានលក្ខណៈខុសប្លែកគ្នាច្រើនពីសិល្បៈតំបន់ហ្គាន់ដារា (Gandhāra) សារនាថ និងមធូរ៉ា (Mathura)ប៉ុន្មាននោះទេ (រូបលេខ១)។ ក្នុងចំណោមបដិមាទ្រង់ឈរ មានកាយវិការសំខាន់ពីរ កាយវិការអភ័យ និងវិតក។ ដោយឡែក មានកាយវិការមួយចំនួនទៀតហាក់មិនសូវជាពេញនិយមនៅស្រុកខ្មែរទេ។ ជាអាទិ៍កាយវិការធម្មចក្រជាដើម។

### កាយវិការអភ័យ

អភ័យមុទ្រ មានន័យថាកាយវិការបំបាត់ភាពភ័យខ្លាច ការធានាសុវត្ថិភាព និងការការពារជាដើម។ បដិមាព្រះពុទ្ធ លើកដៃខាងស្តាំឡើងត្រឹមដើមទ្រូង និងបង្ហាញបាតដៃបែរទៅខាងក្រៅ ហើយម្រាមទាំងអស់ត្រង់ស្មើ។ ជួនកាលគេឃើញបដិមាព្រះអង្គក្នុងទម្រង់ដៃស្តាំលើកត្រឹមដើមទ្រូង និងសណ្តូកដៃឆ្វេងស្របនឹងដងខ្លួន។ ប៉ុន្តែក្នុងករណីខ្លះបាតដៃខាងឆ្វេងបង្ហាញច្បាស់ក្នុងទម្រង់ឱ្យទាន (Varadamudrā) (រូបលេខ២)។ ក្រៅពីការលើកដៃស្តាំតែម្ខាង ពេលខ្លះបដិមាព្រះអង្គលើកដៃទាំងសងខាងតែម្តង (រូបលេខ៣)។ កាយវិការអភ័យ ដែលលើកដៃទាំងពីរឡើងត្រឹមដើមទ្រូង ប្រហែលជាមានទំនោរពីព្រះពុទ្ធសាសនាបែបមហាយាន។

### កាយវិការវិតក

វិតកមុទ្រ គឺជាកាយវិការពិចារណា ជជែកវែកញែក ឬពិភាក្សា។ កាយវិការនេះធ្លាប់បានប្រើប្រាស់ជានិមិត្តសញ្ញាសម្រាប់យោគី និងក្នុងព្រហ្មញ្ញសាសនាផងដែរ។ កាយវិការវិតកអាចប្រើប្រាស់ដៃតែម្ខាង ឬដៃទាំងសងខាងដូចនឹងកាយវិការអភ័យដែរ។ សិល្បករបង្ហាញព្រះពុទ្ធបដិមាលើកដៃតែម្ខាង ឬទាំងសងខាងត្រឹមដើមទ្រូង បាតដៃបែរចេញទៅខាងក្រៅ ហើយម្រាមដៃមេ និងម្រាមដៃចង្អុរភ្ជាប់គ្នា (រូបលេខ៤-៥)។

អត្ថបទដោយៈ មាស សុភាព

## ២. ព្រះពុទ្ធទ្រង់អង្គុយ

ព្រះពុទ្ធបដិមាអង្គុយក្នុងសិល្បៈខ្មែរ ច្រើនតែពែនភ្នែន ដោយដាក់ជើងស្តាំលើជើងឆ្វេង។ ពុទ្ធបដិមាអង្គុយដែលពេញនិយមនៅស្រុកខ្មែរ គឺព្រះពុទ្ធសមាធិប្រក់ដោយនាគ និងផ្ចាញ់មារ។

### ព្រះពុទ្ធប្រក់នាគ

ព្រះពុទ្ធបដិមាប្រក់នាគមានការពេញនិយមបំផុតក្នុងស្រុកខ្មែរ ពិសេសនៅក្នុងរាជព្រះបាទជ័យវរ្ម័នទី៧។ ក្នុងទម្រង់នេះព្រះពុទ្ធទ្រង់អង្គុយពែនភ្នែនសមាធិនៅលើរង្វេលនាគ ដោយដាក់ជើងស្តាំលើជើងឆ្វេង ដៃស្តាំលើដៃឆ្វេង។ ចំណែកក្បាលនាគ បានបើកពពារគ្របពីលើព្រះសិរព្រះពុទ្ធ (រូបលេខ២៦)។ កាយវិការនេះ គឺទាក់ទងទៅនឹងរឿងមួយដែលបានកើតឡើងមុនការត្រាស់ដឹងរបស់ព្រះពុទ្ធ។ ក្នុងគ្រាមួយដែលព្រះអង្គកំពុងអង្គុយសមាធិ មារបានមកផ្ចាញ់ព្រះអង្គដោយបង្អុរព្យុះភ្លៀងបោកបក់យ៉ាងខ្លាំង ដូច្នេះនាគមុជ្ជលិនដែលរស់នៅក្នុងស្រះក្បែរនោះក៏ចេញមកធ្វើជាបល្ល័ង្ក ហើយបើកពពារគ្របការពារព្រះពុទ្ធមិនឱ្យត្រូវទឹកភ្លៀង។

### ព្រះពុទ្ធផ្ចាញ់មារ

ព្រះពុទ្ធផ្ចាញ់មារ ឬព្រះពុទ្ធយកព្រះធរណីជាសាក្សី គឺជាកាយវិការមួយដែលនិយមមកដល់បច្ចុប្បន្ន។ ព្រះពុទ្ធទ្រង់ដាក់ដៃស្តាំ ដោយម្រាមទាំងប្រាំសណ្តូកស្របគ្នា ហើយលាតទៅប៉ះដី (រូបលេខ២៧)។ កាយវិការនេះបញ្ជាក់ពីការផ្ចាញ់មារ និងការត្រាស់ដឹង។ ក្នុងគ្រានោះមារបានបង្កើតហេតុភេតជដើម្បីបង្អាក់ការត្រាស់ដឹងរបស់ព្រះពុទ្ធ ប៉ុន្តែមិនទទួលបានជោគជ័យឡើយ ក៏ព្រោះតែព្រះអង្គបានតាំងចិត្តមាំនិងមិនរង្គោះរង្គើររបស់ព្រះអង្គ។[៨] បន្ទាប់មកទ្រង់ក៏យកដៃរបស់ព្រះអង្គលាតប៉ះដីនឹករលឹកជាតិកំណើត និងយកព្រះធរណីជាសាក្សីចំពោះការត្រាស់ដឹង ។

[៨] Filigenzi, ‘Gestures and Things’, 112.

### ៣. ព្រះពុទ្ធចូលនិព្វាន

ព្រះពុទ្ធចូលនិព្វានមានការពេញនិយមក្នុងព្រះពុទ្ធសាសនាបែបថេរវាទ។ កាយវិការនេះមានន័យពីរ ទី១បង្ហាញថាព្រះអង្គមានជំងឺធ្ងន់ និងទី២ព្រះអង្គចូលបរិនិព្វាន។[៩] ព្រះអង្គបានដាក់ខ្លួនផ្នែកខាងស្តាំទំរេតចុះ ដៃឆ្វេងសណ្តូកលើខ្លួនខាងឆ្វេង ហើយព្រះសិរកើយលើដៃស្តាំ (រូបលេខ៦៨)។ នៅថ្ងៃ១៥កើត ខែពិសាខ (ឧសភា) ក្នុងតំបន់គុសីនគរ[១០] ព្រះអង្គបានដាក់ខ្លួនទំរេតបែរទៅខាងជើង លើកម្រាលដែលអនន្ទបានរៀបចំ ហើយអនុញ្ញាតឱ្យសួរនៅចម្ងល់ដែលនៅសេសសល់។ បន្ទាប់មកព្រះអង្គក៏ចូលបរិនិព្វានក្នុងគ្រានោះ។

សរុបមក កាយវិការរបស់ព្រះពុទ្ធក្នុងសិល្បៈខ្មែរ ដែលមានការពេញនិយមពីសម័យបុរាណរហូតមកដល់ពេលបច្ចុប្បន្នមាន កាយវិការអភ័យ វីតក សមាធិប្រក់ដោយនាគ ផ្ចាញ់មារ និងចូលបរិនិព្វាន។



រូបលេខ២១ ព្រះពុទ្ធកាយវិការអភ័យ (ស្រុកឥណ្ឌា)



រូបលេខ២២-៣ ព្រះពុទ្ធឈរកាយវិការអភ័យ ទាំងពីរទម្រង់

[៩] Padmanabha, 'The Buddha Image in Sculptural Arts of India', 94.

[១០] Abeysekera, *The Life of the Buddha*, 35.



រូបលេខ២៤៖ ព្រះពុទ្ធកាយវិការវីតក
(ប្រភពសារមន្ទីរជាតិកម្ពុជា)



រូបលេខ២៥៖ ព្រះពុទ្ធលើកដៃទាំងពីរក្នុងកាយវិការវីតក
(មកពីទួលព្រះធាតុ បច្ចុប្បន្ននៅសារមន្ទីរហ្គីមេ)



រូបលេខ២៦៖ ព្រះពុទ្ធប្រក់នាគ



រូបលេខ២៧៖ ព្រះពុទ្ធផ្ចាញ់មារ អំពីប្រាក់
(ប្រភពសារមន្ទីរជាតិកម្ពុជា)

អត្ថបទដោយ៖ មាស សុភាព



រូបលេខ៨ ព្រះពុទ្ធចូលនិព្វាន (ភ្នំគូលែន)

## ឯកសារពិគ្រោះ


Abeysekera, Radhika. *The Life of the Buddha*. R. Abeysekera, 1991.

Filigenzi, Anna. 'Gestures and Things: The Buddha's Robe in Gandharan Art'. *East and West* 55, no. 1/4 (2005): 103–16.

Huntington, Susan L. 'Early Buddhist Art and the Theory of Aniconism'. *Art Journal* 49, no. 4 (1990): 401–8. https://doi.org/10.2307/777142.

Padmanabha, K. 'The Buddha Image in Sculptural Arts of India'. *The Tibet Journal* 20, no. 4 (1995): 93–98.


AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION